HONEYCOMB 2/1 (January 2001): 77–85



# Training Adults to Become Christians in the Catholic Church

*François PONCHAUD*

After Jesus rose from the dead he instructed his eleven disciples, "Therefore go and make disciples of all nations, baptizing them in the name of the Father and of the Son and of the Holy Spirit, and teaching them to obey everything I have commanded you" (Matt 28:19–20).

Many biblical scholars conclude that the gospel of Matthew gives more attention to church organization than do the other synoptic gospels. In the verse cited above, Matthew points to the baptism that the early church conducted for new converts in A.D. 80. Maybe Jesus himself did not speak as clearly as does this passage, but it confirms what the churches practiced forty to fifty years after his death. According to Matthew, Jesus did not only send the apostles to evangelize, but charged them with "baptism" and "teaching the people to obey what he had commanded them to do." The baptism and deeds expressed the faith of those who gave their lives to Jesus as Christ and Lord.

Therefore since the beginning of the church, we can see in the Acts of the Apostles Christians who have concentrated on two tasks: sharing the good news of salvation brought by Jesus, and training others to become disciples.

After Peter proclaimed Christ's resurrection, "with many other words he warned them, and he pleaded with them" (Acts

2:40). The early Christians "devoted themselves to the apostles' teaching and to fellowship . . . and prayer" (Acts 2:42). After Paul converted to faith in the Jesus whom he had persecuted, he was educated and baptized by Ananias (Acts 9:5, 17–19).

From the second until the fourth centuries there were not many Christians, and this minority suffered persecution under the authorities. Therefore the church was *eager* to teach adults to be Christians. Tertullian (A.D. 150), Origen (A.D. 180), and Cyprian (A.D. 250) were famous in teaching people. Later, after the state became Christian, believers did not pay much attention to instructing and converting adults. They only performed baptism for newly-born children. Then in 1963 the second Vatican council decided to teach adults who wish to become Christians in accordance with the ancient way. This way is appropriate to the situation of Cambodia, since there are a small number of Christians living among a majority of Buddhists who hold to a faith very different from Christianity.

Normally the Catholic Church does not quickly perform baptism for those who ask to become Christians, but waits until they have gone through these four phases of formation:

1. initial evangelization
2. educating them to become disciples (catechumenate)
3. preparing them to receive the sacrament of baptism and the body of Christ
4. having neophytes reflect on the new life that they have received (mystagogy)

## 1. First phase—Evangelization

Every Christian has an important obligation to preach the gospel of salvation through Jesus. As the apostle Paul said, "Woe to me if I do not preach the gospel!" (1 Cor 9:16). This is the task every one of us must do. If we know the way that provides happiness for us, we must share it to others. We cannot keep it only for ourselves! We preach the gospel through various ways, such as visiting people and caring for their living situation, just as Jesus took care of the living situation of people. We share with them and inquire about their faith. What do they want? What do they

understand of the meaning of their lives? How does their religion solve their problems? How do they experience their spiritual lives? Usually our Catholic brothers do not like to stress verbal religious proclamation because faith is a kind of love story. It is mysterious; we cannot share it with friends in a public area. On the other hand, we believe that the Holy Spirit—who is the spirit of Jesus risen from the dead—dwells in those who are devoted to their religion. He called them and exhorted them through the various ways of their own religion as well. We just try to be a witness to the way that leads to God, whom people are seeking through their own religions. We try our best to understand their deep desires and pay attention to respond to their needs as well.

The people who convert to Jesus are most likely to become the ones who change the direction of their lives. They change their minds not because they learned a theory or studied the Bible, but because they met Jesus—the living God—and accepted Him as their refuge. He leads them to change their thinking, behavior, relationships with others in society, relationships with men and women, manner of living as husband and wife, way of loving others, etc.

Sometimes those who accept the gospel believe immediately in Jesus as their savior, but they do not obey the good news as described in the parable of Good Seed (Mk 4:1–9). Sometimes it will take a few years—or ten to twenty years—for them to really depend on Jesus according to the Father who "draws them" (John 6:44), and according to their answer also. In this phase the candidate reveals his[1] desire to become a Christian. Perhaps a person met a Christian who proclaimed the gospel in a confusing way—for example that the church saves mankind through giving money or rice, etc. In this case the church should help purify their desires and teach them to entrust their lives to Jesus, who shows the new way to the Father. That person then accepts Jesus as "the way, the truth, and the life" (John 14:6). He is willing to turn away from his old way, to know Jesus, and live for Him. If the person gains

[1]For the sake of convenience and euphony, in this article masculine pronouns used for people in general refer to women as well as men.

some kind of understanding then the church will conduct a ritual called "entering the church ceremony."

The church decides whether or not to accept this new member by considering some aspects of his faith and character:

- The person who applies for church membership must believe that Jesus is not the Father and not the Holy Spirit.
- Because he has met Christ the living God, he eagerly proclaims the Gospel to others.
- He must turn away from depending on the Buddha and trust in Christ instead. That does not mean we reject Buddhism, but rather that we Christians choose another way. We cannot reach Battambang by taking a bus and at the same time boarding a plane.
- He is not afraid of ghosts, and no longer consults with fortunetellers or mediums.
- He has started to care for other people who are poorer than he, striving for justice in society with all his strength.
- He is glad to join with other people who are seeking Jesus as he is.
- He is faithful to his spouse, no more playing cards, no more drunkenness, no more doing inappropriate business (especially oppressing others), no more receiving bribes, etc.
- If he is still young, the parents must be willing to let their child become a Christian.

Then the church accepts him as a Christian even though that person has not yet participated in a baptism ceremony.

## 2. Second Phase—Train Them to be Disciples.

Jesus told the group of his apostles "to make disciples of all nations" and "teach them to obey everything I have commanded" (Matt 28:19). The Church Fathers made a new word for that phase of "teaching them to become disciples": *discipleship*. It takes a long time to become a disciple. Baptism does not mean that a person is a disciple.

The person who is already a member of the church has to receive instruction in three major areas: knowing God's Word, knowing how to pray, and living according to Jesus' teaching.

According to the book of Acts, the early church devoted itself to the apostles' teaching, to fellowship, and to prayer (Acts 2:42).

The ones who received instruction in the faith "devoted themselves to the apostles' teaching." The person who hears the Word of God not just learns about the Bible, but gradually recognizes that God the Father loves him and calls that person to make a covenant with Him as if God were asking to marry him. When we study the Bible we discover a kind of love story, because the history of salvation in the Bible reads like a love story and the gift of life. The believer responds to God who loves him. Regulations come out of love also; therefore, the catechumen must consider his manner of living. He needs to bring his lifestyle in accordance with the love of God. The person who "teaches the Bible" must be a witness, who by his own living example shares his experience. A Bible teacher is not just one who teaches the Bible's words.

"They devoted themselves to prayer": the catechumen receives instruction on how to pray on his own as a Christian. Every religion teaches people to pray or to recite prayers, but only Jesus teaches people to have a spiritual relationship with the Father through the enlightenment of the Holy Spirit. So we have to teach them to pray the way that Jesus taught in Matt 6:5–13, particularly verses 9–13. The prayer was the "Our Father"; this is a model for Christian prayer. The person who receives instruction on prayer prays to the Father with love, using the words and the mindset of Jesus.

They "devoted themselves to fellowship." Members of the early church shared their possessions with one another. This means that Christian living is different from the lifestyle of other people. It is not preoccupied with earning for one's own consumption with no consideration for the poor. This is a very crucial point, showing that the candidate has experienced true conversion—not only lip conversion. The catechumen receives instruction on how to live according to his Master's teaching. People are to love others and forgive those who wrong them. Such practice is very different from what people normally do. Then they are to reflect on the message that Jesus shared on the mountain (Matt 5–7). He revealed that the way that leads to true happiness differs from the way of happiness

of the world. Everybody must obey Moses' law; only Christians obey the new commandment of Jesus.

This phase may take a long time—maybe one or two years. In this phase various rituals are performed, such as transmission of Jesus' prayer (Matt 6:9–13), meaning Christians should testify that they live according to the words of this prayer to let the seekers listen. Sometimes the ceremony of the gift of Jesus' word on true happiness (Matt 5:1–12) is held. Sometimes a ritual is performed using the brief Christian creed formulated by the church leaders in Nicea (A.D. 325). In this way the new convert understands that he has received the faith that was preached by the apostles and has been proclaimed from one generation to the next until today.

### 3. Third Phase—Candidates Preparing Themselves to Receive Baptism and Holy Communion

For many generations the church has celebrated Lent for all Christians to prepare themselves for forty days to commemorate the death and resurrection of Jesus. Then the church conducted a special teaching for the catechumens. During this time they read passages to remind them of baptism—Jesus tempted by Satan (Matt 4:1–11), Jesus undergoing a transfiguration (Matt 17:19), Jesus talking with a Samaritan woman (John 4:5–42), Jesus healing a man born blind (John 9:41), Jesus raising Lazarus from the dead (John 11:44). The whole church teaches those who want to receive baptism during Lent so that they know the way of Jesus—that they need to fight Satan, but that this way leads to the glory of God. When they receive the sacrament of baptism Jesus gives them a source of life that will provide eternal life. He enlightens their minds and raises them from the dead.

Normally the bishop performs water baptism for them in the night of the Passover ceremony to declare that those who receive baptism also share the death and resurrection of Christ. As Paul said, "Or don't you know that all of us who were baptized into Christ Jesus were baptized into his death? We were therefore buried with him through baptism into death. . . . If we have been united with him in his death, we will certainly also be united with him in his resurrection" (Rom 6:3–5).

### 4. Fourth phase—Reflection on the Wonderful New Life that Christians Receive through Christ.

After the Passover ceremony the neophytes reflect together on the dignity of their new life for at least fifty days.

The Church Fathers frequently compare adults who want to become Christians to the conception of a baby in his mother's womb, or to an Israelite who left Egypt for Canaan.

Jesus compared the sacrament of baptism to a new birth (John 3:3–8, "I tell you the truth, no one can see the kingdom of God unless he is born again. . . . I tell you the truth, no one can enter the kingdom of God unless he is born of water and the Spirit"). But infants stay in the womb for nine months before they are born. A wife receiving sperm from her husband resembles a believer receiving the Word of God. When he first receives the Good News, his faith is like the conception of a child, but it is still small like the fetus in the mother's womb. Then the catechumens show their behavior, meaning that they are willing to follow Jesus who called them. They want to know Him more and more as their good teacher, and they decide to totally give themselves to Him who is the real source of life. They begin to believe when they "join the church" with an auspicious ceremony. When they join the church that means they are "Christian."

The fetus spends a long time in the womb in order to grow physically. Similarly, a new convert to Jesus as savior needs time to grow spiritually. He must not only learn but also practice how to live like Christ and follow him whom he has met as the living God.

This comparison helps us understand that we need time to let faith grow, just as a fetus needs time to mature enough to become a baby. If a baby is born after sufficient time in the womb he will live. If he is born before adequate time he will either be premature or miscarry and will not live. If he is delayed in delivery he will die in his mother's womb. That is why we don't rush to perform baptism, but allow time to assure that the new faith is certain and not transitory. Nor do we delay too long, or the individual might lose interest and his faith die out.

This comparison also helps us realize that teaching catechumens does not consist simply of verbal "instructions," but

also of training in living the Christ's way. The whole church is like a mother who nourishes the fetus in her womb; it is not just two or three people who perform that task.

All Christians educate newcomers by setting the example of genuinely loving each other, and by conducting various ceremonies. The newcomer helps the church to realize her role of a mother who loves, educates, and feeds her son.

The Church Fathers also compare the instruction of catechumens to the exodus from Egypt toward Canaan. This was a very crucial event in the history of God's people. God called his people out of slavery in Egypt. He parted the Red Sea, led them through, and gave the Law on Mount Sinai. He seemed to say: "I love all of you, but do you love Me? I speak the Word, but do you obey it?" The Israelites sinned against God by worshiping the golden calf. Therefore God tested their hearts for forty years.

Origen, a second-century Egyptian, was a renowned teacher of the faith. He used to give this example to teach catechumens: "Brothers, you left the Gentile world and gave up the worship of other gods in Egypt! You became the people of God. You began to walk. You received instruction in the faith, just as the Israelites did when they wandered in the wilderness. You received the Mosaic Law and Jesus' commandments, and began living a life according to Jesus' instructions. When you attempted to live the new way of life, priests helped by leading you across the Jordan River. You will receive baptism in the Jordan like Christ. Then you will enter the Promised Land to rest with Christ."

This comparison helps us understand that faith is like a journey with Jesus—a journey consisting of phases. The catechumens walk with the whole church they listen to God's Word together with other Christians. This process is a little bit different, but we must try our best to live according to the Gospel of Jesus.

All the Church Fathers used to compare baptism to a wedding, which also has different phases such as the proposal, engagement, bringing presents to the bride, the wedding ceremony, and living together.

The way in which the Catholic Church instructs the catechumens is the way that Christians have practiced ever since the beginning. God touches the hearts so that people believe, but

we have the obligation to educate people in the faith. Origen stated that "They approach faith, enter faith, confess faith, and live by faith." Jesus also desires that believers unite themselves into one great family by living His new way of life and changing the world according to God's will. Faith influences the world.

សំណុំធីកឃុំ ២/១ (មករា ២០០១)៖ ៨៦-៩៨



# ការបង្ហាត់មនុស្សពេញវ័យឲ្យទៅជាគ្រីស្តបរិស័ទតាមរបៀបព្រះសហគមន៍កាតូលិក

*លោកបូជាចារ្យ ហ្វ្រង់ស្វ័រ ប៉ុងសូដ៏*

កាលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ព្រះអង្គមានព្រះបន្ទូលទៅកាន់ក្រុមគ្រីស្តទូតទាំងដប់មួយនាក់ថា៖ *"ចូរចេញទៅ! នាំមនុស្សគ្រប់ជាតិសាសន៍ឲ្យធ្វើជាសាវ័ក ហើយធ្វើពិធីជ្រមុជទឹកឲ្យគេ ក្នុងនាមព្រះបិតា ព្រះបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធ ។ ត្រូវបង្រៀនគេឲ្យប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា"* (ម៉ាថាយ ២៨:១៩) ។

អ្នកវិភាគគម្ពីរតែងសន្និដ្ឋានថា គម្ពីរដំណឹងល្អតាមលោកម៉ាថាយគូសសង្កត់លើព្រះសហគមន៍[១] គឺក្រុមគ្រីស្តបរិស័ទ ដែលជឿលើព្រះគ្រីស្ត ជាងជឿលើគម្ពីរដំណឹងល្អទាំងបីក័ណ្ឌទៅទៀត ។ ក្នុងឃ្លាខាងលើនេះ លោកម៉ាថាយចែងអំពីពិធីជ្រមុជទឹក ដែលព្រះសហគមន៍ដើមដំបូងធ្លាប់ធ្វើជូនអ្នកជឿថ្មី នៅគ.ស ៨០ ។ ប្រហែលព្រះយេស៊ូមិនមានព្រះបន្ទូលច្បាស់យ៉ាងនេះទេ គឺអត្ថបទនេះ បញ្ជាក់អំពីរបៀបព្រះសហគមន៍ប្រព្រឹត្ត ៤០-៥០ ឆ្នាំ ក្រោយព្រះយេស៊ូសោយទិវង្គត ។ តាមលោកម៉ាថាយ ព្រះយេស៊ូមិនគ្រាន់តែចាត់គ្រីស្តទូតឲ្យទៅប្រកាសជំនឿប៉ុណ្ណោះ

---

[១] *ព្រះសហគមន៍ ៗ "ក្រុមជំនុំ" សំដៅទៅលើក្រុមគ្រីស្តបរិស័ទទាំងអស់ជាព្រះកាយព្រះគ្រីស្ត ៗ*

ទេ គឺអោយធ្វើ *"ពិធីជ្រមុជទឹក"* ថែមទៀត និងឲ្យ *"បង្រៀនគេ ឲ្យប្រតិបត្តិតាមសេចក្តី"* ដែលព្រះអង្គបានបញ្ជាដល់គេដែរ ។ ពិធីជ្រមុជទឹក និងកិច្ចការ ដែលមនុស្សប្រព្រឹត្តនោះ មុខជាបញ្ជាក់ជំនឿរបស់អ្នកធ្វើជីវិតលើព្រះយេស៊ូ ជាព្រះគ្រីស្ត និង ជាព្រះអម្ចាស់ ។

ហេតុនេះ តាំងពីដើមដំបូងរៀងមក ក្នុងគម្ពីរកិច្ចការគ្រីស្តទូតក្តី យើងអាចសង្ខេបឃើញថា គ្រីស្តបរិស័ទយកចិត្តទុកដាក់ និងបំពេញភារកិច្ចពីរយ៉ាង គឺ គេប្រកាសដំណឹងល្អស្តីពីការសង្គ្រោះដោយសារព្រះយេស៊ូ ហើយបង្ហាត់បង្រៀនអ្នកជឿឲ្យធ្វើជាសាវ័ក ។ ឧប. ក្រោយពីលោកសីលា ប្រកាសដំណឹងល្អ អំពីព្រះគ្រីស្តមានព្រះជន្មរស់ឡើងវិញ លោក *"ពន្យល់បញ្ជាក់ និង ដាស់តឿនគេ ដោយពាក្យពេចន៍ជាច្រើន ទៀត"* (កិច្ចការ ២:៤) ។ គ្រីស្តបរិស័ទដើមដំបូង *"ព្យាយាមស្តាប់សេចក្តីបង្រៀនរបស់ក្រុមគ្រីស្តទូត ព្យាយាមរួមរស់ជាមួយគ្នា . . . និងព្យាយាមអធិដ្ឋាន"* (កិច្ចការ ២:៤២) ។ លោក ប៉ូល ប្រែចិត្តជឿលើព្រះយេស៊ូ ដែលគាត់បៀតបៀនធ្វើបាបនោះ ទទួលការអប់រំពីលោកអណាញ៉ាស រួចទទួលពិធីជ្រមុជទឹក (កិច្ចការ ៩:៥; ១៧-១៩) ។

នៅសតវត្សទី ២ ដល់ទី ៤ នៃគ្រីស្តសករាជ គ្រីស្តបរិស័ទមានចំនួនដ៏តិចតួច ហើយត្រូវរដ្ឋអំណាចបៀតបៀនធ្វើបាបទៀតផង ។ ហេតុនេះ ព្រះសហគមន៍របស់ព្រះគ្រីស្តបរិស័ទ យកចិត្តទុកដាក់ជាខ្លាំង ដើម្បីបង្ហាត់មនុស្សពេញវ័យឲ្យទៅជាគ្រីស្តបរិស័ទ ។ មានលោក ទែរតូលីយ៉ាំង (គ.ស ១៥០) លោកង្ហូរីសែន (គ.ស ១៨០) លោកស៊ីព្រីយ៉ាំង (គ.ស ២៥០) ជាបុព្វបុរស ដែលមានឈ្មោះល្បី ក្នុងការបង្ហាត់មនុស្សឲ្យទៅជាគ្រីស្តបរិស័ទ ។ ក្រោយមក ដោយរដ្ឋអំណាចក្លាយទៅជាកាន់គ្រីស្តសាសនា គ្រីស្តបរិស័ទមិនសូវយកចិត្តទុកដាក់ប្រកាសដំណឹងល្អ និងបង្ហាត់មនុស្សពេញវ័យទេ ហើយគ្រាន់តែនាំគ្នាធ្វើអគ្គសញ្ញាជ្រមុជទឹកឲ្យកូនក្មេង ដែលទើបនឹងកើតតែប៉ុណ្ណោះ ។ នៅឆ្នាំ ១៩៦៣ អស់លោកអភិ

បាលព្រះសហគមន៍កាតូលិក ជួបជុំគ្នាជាមហាសន្និបាតវ៉ាទីកងទី ២ អស់លោកបានសម្រេចនឹងបង្ហាត់មនុស្សពេញវ័យឲ្យទៅជាគ្រីស្តបរិស័ទ តាមរបៀបពីបូរាណមក ។ របៀបនេះ ស្របនឹងកាលៈទេសៈរបស់ប្រទេសកម្ពុជា ដែលមានគ្រីស្តបរិស័ទមួយចំនួនតូច ហើយប្រជាជនភាគច្រើនកាន់ពុទ្ធសាសនា ដែលមានជំនឿប្លែកពីគ្រីស្តសាសនាយ៉ាងខ្លាំង ។

ធម្មតា ព្រះសហគមន៍កាតូលិក គ្មានការប្រញាប់នឹងធ្វើពិធីជ្រមុជទឹកឲ្យអ្នក ដែលសុំស្គាល់ព្រះយេស៊ូ ដែលធ្លាប់អប់រំគេ តាមដំណាក់កាលបួននេះទេ៖

១- *ការប្រកាសដំណឹងល្អដើមដំបូង (first evangelisation)*
២- *ការបង្ហាត់បង្រៀនឲ្យទៅជាសាវ័ក (catechumenate)*
៣- *ការរៀបចំខ្លួន និង ទទួលអគ្គសញ្ញា[២] ជ្រមុជទឹក និង ព្រះកាយ ព្រះគ្រីស្ត*
៤- *ពន្លក (neophyte) ស្វែងយល់អំពីជីវិតថ្មី ដែលខ្លួនបានទទួល (mystagogy)*

## ១- ដំណាក់កាលទី ១ ការប្រកាសដំណឹងល្អ

គ្រីស្តបរិស័ទគ្រប់ៗរូបមានភារកិច្ចដ៏សំខាន់ គឺប្រកាសដំណឹងល្អស្តីអំពីការសង្គ្រោះ ដោយសារព្រះយេស៊ូ ដូចគ្រីស្តទូត ប៉ូល ថែងថា "*ប្រសិនបើខ្ញុំមិនផ្សាយដំណឹងល្អទេ សូមឲ្យខ្ញុំទៅវេទនាចុះ!*" (១កូរិនថូស ៩:១៦) ។ នេះជាភារកិច្ចមួយ ដែលយើងម្នាក់ៗ "*ត្រូវតែធ្វើ ដោយខានមិនបាន*" ។ ប្រសិនបើយើងបានទទួលស្គាល់ផ្លូវ ដែលផ្តល់សេចក្តីសុខសាន្តដល់ខ្លួន យើងត្រូវតែចែករំលែកដល់អ្នកដទៃ យើងមិនអាចលាក់

---

[២] *អគ្គសញ្ញា គឺសញ្ញាដ៏ប្រសើរ ដូចជាពិធីជ្រមុជទឹកជាដើម ជាពិធីមួយបង្ហាញបញ្ជាក់ជំនឿរបស់អ្នកទទួល និង បញ្ជាក់ថា ព្រះជាម្ចាស់ប្រោសប្រណីដល់មនុស្សមែន ។*

ទុកសម្រាប់តែខ្លួនឯងទេ! ។ យើងប្រកាសដំណឹងល្អតាមរបៀបផ្សេងៗ ដោយទៅសួរសុខទុក្ខគេ ដោយយកចិត្តទុកដាក់នឹងការរស់នៅរបស់គេ ដូចព្រះយេស៊ូ ដែលយកចិត្តទុកដាក់នឹងជីវភាពអ្នកស្រុក ។ យើងនិយាយសន្ទនាជាមួយគេ និង រិះគិតជាមួយគេអំពីសាសនារបស់ខ្លួនថា តើគេចង់បានអ្វី? គេយល់យ៉ាងណាអំពីអត្ថន័យនៃជីវិតរបស់គេ? តើសាសនារបស់គេជួយដោះស្រាយបញ្ហាជីវិតរបស់គេយ៉ាងណា? តើគេមានការពិសោធន៍យ៉ាងណា អំពីជីវិតខាងព្រះវិញ្ញាណ? ។ តាមធម្មតាបងប្អូនកាតូលិកមិនចូលចិត្តឃោសនាអំពីសាសនាទេ ព្រោះជំនឿប្រៀបដូចជារឿងស្នេហាម៉្យាង ជារឿងអាថ៌កំបាំង ដែលយើងមិនអាចប្រាប់ដល់មិត្តសំឡាញ់លើទីសាធារណៈបានទេ ។ ម៉្យាងទៀត យើងជឿជាក់ថា ព្រះវិញ្ញាណដ៏វិសុទ្ធ គឺព្រះវិញ្ញាណរបស់ព្រះយេស៊ូ ដែលមានព្រះជន្មរស់ឡើងវិញ ព្រះអង្គគង់នៅជាមួយអស់អ្នក ដែលកាន់សាសនារបស់ខ្លួនដោយចិត្តស្មោះ ព្រះអង្គត្រាស់ហៅគេ និង ដាស់តឿនគេ តាមរបៀបផ្សេងៗ មានសាសនារបស់ខ្លួនគេជាដើម ។ យើងគ្រាន់តែខិតខំធ្វើជាសាក្សីអំពីមាគ៌ា គឺផ្លូវមួយផ្សេងទៅកាន់ព្រះជាម្ចាស់ ដែលមនុស្សទាំងអស់ស្វែងរកតាមសាសនាផ្សេងៗ ។ យើងខិតខំយល់បំណងដ៏ជ្រៅរបស់គេ ហើយយកចិត្តទុកដាក់តបឆ្លើយនឹងបំណងរបស់គេផងដែរ ។

អ្នកប្រែចិត្តគំនិត ទៅពឹងលើព្រះយេស៊ូ ហាក់ដូចជាអ្នកដូរទិសនៃជីវិតរបស់គេ គេដូរគំនិតមិនមែនមកពីគេរៀនសូត្រទ្រឹស្ដី ឬ រៀនគម្ពីរទេ គឺមកពីគេបានជួបព្រះយេស៊ូ ដែលមានព្រះជន្មគង់នៅ ហើយចង់ទទួលយកព្រះអង្គមកធ្វើជាទីពឹង ។ ព្រះអង្គនាំគេឲ្យប្រែរបៀបគិតគូរឲ្យប្រែកិរិយាមារយាទរបស់ខ្លួន ប្រែទំនាក់ទំនងជា មួយអ្នកដទៃក្នុងសង្គម ជាមួយប្រុសជាមួយស្ត្រី របៀបរស់នៅជាគូស្វាមីភរិយា របៀបគេស្រឡាញ់អ្នកដទៃ ។ល។

ជួនកាល អ្នកទទួលដំណឹងល្អនេះ ជឿលើព្រះយេស៊ូជាព្រះសង្គ្រោះភ្លាម តែមិនប្រព្រឹត្តតាមដំណឹងល្អនោះ ដូចមានចែងក្នុងព្រះបន្ទូលប្រស្នាស្តីអំពីគ្រាប់ពូជទេ (ម៉ាកុស ៤:១-៩) ។ ជួនកាល ត្រូវការពីរបីឆ្នាំ ឬ ដប់ម្ភៃឆ្នាំទៀត ទើបគេយកព្រះយេស៊ូជាទីពឹងដ៏ពិតប្រាកដ គឺស្រេចតែព្រះបិតា *"ទាក់ទាញចិត្តគេ"* (យ៉ូហាន ៦:៤៤) និង ស្រេចតែចម្លើយរបស់គេដែរ ។ ក្នុងដំណាក់កាលនេះ បេក្ខជនសំដែងបំណងរបស់ខ្លួន ដែលចង់ទៅជាគ្រីស្តបរិស័ទ គាត់បានជួបគ្រីស្តបរិស័ទ ដែលប្រកាសដំណឹងល្អ តែជួនកាលយល់ច្រឡំ ដោយស្មានថា ព្រះសហគមន៍សង្គ្រោះគេតាមមនុស្សលោក ផ្តល់លុយកាក់ ឬ អង្ករ ។ល។ ព្រះសហគមន៍ក៏ជួយគេឲ្យជម្រះបំណងរបស់គេ ហើយដាស់តឿនគេឲ្យផ្ញើជីវិតលើព្រះគ្រីស្ត ដែលបង្ហាញមាគ៌ាថ្មីទៅកាន់ព្រះបិតាដែរ ។ អ្នកនោះទទួលព្រះយេស៊ូទុក *"ជាផ្លូវ ជាសេចក្តីពិត និងជាជីវិត"* (យ៉ូហាន ១៤:៦) ។ គេសុខចិត្តលះបង់ផ្លូវចាស់ចោល ចង់ស្គាល់ព្រះអង្គ ចង់រួមរស់ជាមួយព្រះអង្គ ។ បើពិតដូច្នេះមែន នៅពេលនោះ ព្រះសហគមន៍ចាត់ចែងពិធីមួយ ហៅថា *"ពិធីចូលព្រះសហគមន៍"* ។

**ព្រះសហគមន៍សម្រេចទទួលគេដោយរិះគិតអំពីលក្ខណៈខ្លះគឺ៖**

- អ្នកដែលសូមចូលព្រះសហគមន៍ ត្រូវចាប់ផ្តើមជឿលើព្រះយេស៊ូជាព្រះគ្រីស្ត និង ជាព្រះសង្គ្រោះរបស់ខ្លួន ។ ត្រូវយល់ថា ព្រះយេស៊ូមិនមែនជាព្រះបិតា ហើយក៏មិនមែនជាព្រះវិញ្ញាណដ៏វិសុទ្ធដែរ ។
- អ្នកនោះត្រូវមានអំណរសប្បាយខ្លះក្នុងចិត្ត ដោយបានជួបព្រះគ្រីស្ត ដែលមានព្រះជន្មគង់នៅ ហើយយកចិត្តទុកដាក់ចែករំលែកដំណឹងល្អនេះឲ្យអ្នកដទៃផង ។
- អ្នកនោះលែងយកព្រះពុទ្ធជាទីពឹង គឺបែរទៅរកព្រះគ្រីស្តជាទីពឹង ។ សេចក្តីនេះមិនសំដៅថា យើងមិនពេញចិត្តនឹងពុទ្ធសាសនា

ទេ តែត្រូវជ្រើសរើសផ្លូវមួយ យើងមិនអាចទៅក្រុងបាត់ដំបងបាន ដោយជិះឡានផង ជិះយន្តហោះផងទេ ។

- អ្នកនោះលែងខ្លាចខ្មោច លែងទៅសួរហោរ លែងទៅបញ្ជាន់អារក្ខ ។
- គេចាប់ផ្ដើមយកចិត្តទុកដាក់នឹងអ្នកដទៃ អ្នកក្រជាងខ្លួនរកយុត្តិធម៌ក្នុងសង្គមតាមកម្លាំងរបស់ខ្លួន ។
- គេសប្បាយចិត្ត ដោយចូលរួមជាមួយអ្នក ដែលស្វែងព្រះយេស៊ូដូចគ្នា ។
- មានចិត្តភក្ដីនឹងគូរបស់ខ្លួន លែងលេងបៀរ លែងស្រវឹងស្រា លែងរកស៊ីផ្ដេសផ្ដាស ជាពិសេសដោយជិះជាន់អ្នកដទៃ លែងស៊ីសំណូក ។ល។
- ប្រសិនបើអ្នកនេះនៅក្មេង ឪពុកម្ដាយត្រូវពេញចិត្តឲ្យកូនទៅជាគ្រីស្ទបរិស័ទ ។

ពេលនោះព្រះសហគមន៍ ទទួលគេទុកជាគ្រីស្ទបរិស័ទ ទោះបីគេមិនទាន់ទទួលអគ្គសញ្ញាជ្រមុជទឹកក៏ដោយ ។

## ២- ដំណាក់កាលទី ២ គឺពេលបង្ហាត់ឲ្យទៅជាសាវ័ក

ព្រះយេស៊ូបានផ្ដាំក្រុមគ្រីស្ដទូតឲ្យ *"នាំមនុស្សគ្រប់ជាតិសាសន៍ ធ្វើជាសាវ័ក"* និង *"បង្រៀនគេឲ្យប្រតិបត្តិតាមសេចក្ដីទាំងប៉ុន្មានដែលខ្ញុំបានបង្គាប់"* ឲ្យគេ (ម៉ាថាយ ២៨:១៩) ។ បុព្វបុរសនៃព្រះសហគមន៍គ្រីស្ដបរិស័ទបានបង្កើតពាក្យថ្មីសំដៅទៅលើតំណាក់កាលនេះ គឺ *"រយៈពេលបង្ហាត់គេឲ្យទៅជាសាវ័ក"* (Discipulat) ។ ត្រូវចំណាយពេលវេលាយ៉ាងយូរ ដើម្បីឲ្យទៅជាសាវ័ក ទោះបីអ្នកទទួលអគ្គសញ្ញាជ្រមុជទឹកក្ដី ក៏មិនទាន់ក្លាយជាសាវ័កពិតប្រាកដដែរ ។

អ្នកដែលចូលព្រះសហគមន៍រួចហើយ ទទួលការអប់រំ ៣ វិស័យដ៏សំខាន់ គឺ៖ ឲ្យគេស្គាល់ព្រះបន្ទូល ឲ្យចេះអធិដ្ឋាន និង ឲ្យរស់នៅតាមគន្លងធម៌របស់ព្រះគ្រីស្ត គឺស្របតាមដំណឹងល្អរបស់ព្រះអង្គ ដូចមានចែងក្នុងគម្ពីរ "*កិច្ចការគ្រីស្តទូត*" អំពីព្រះសហគមន៍គ្រីស្តបរិស័ទដើម គឺពួកគេ "*ព្យាយាមស្តាប់សេចក្តីបង្រៀនរបស់គ្រីស្តទូត ព្យាយាមរួមរស់ជាមួយគ្នា . . . និង ព្យាយាមអធិដ្ឋាន*" (កិច្ចការ ២:៤២) ។

អ្នកទទួលការអប់រំជំនឿ "*ព្យាយាមស្តាប់សេចក្តីបង្រៀនរបស់ក្រុមគ្រីស្តទូត*" ។ អ្នកស្តាប់ព្រះបន្ទូលមិនគ្រាន់តែរៀនគម្ពីរទេ គឺទទួលស្គាល់បន្តិចម្តងៗថា ព្រះជាម្ចាស់ជាព្រះបិតា ដែលស្រឡាញ់គាត់ ហើយត្រាស់ហៅគាត់ឲ្យចងសម្ពន្ធមេត្រីជាមួយព្រះអង្គ ដូចព្រះអង្គសុំរៀបអាពាហ៍ពិពាហ៍ជាមួយ ។ ពេលយើងសិក្សាអំពីគម្ពីរ យើងចូលក្នុងរឿងស្នេហាម៉្យាង ព្រោះប្រវត្តិនៃការសង្គ្រោះ ដែលមានចែងក្នុងព្រះគម្ពីរ ប្រៀបដូចជារឿងស្នេហា និង អំណោយទាននៃជីវិត ។ អ្នកជឿតបឆ្លើយនឹងព្រះជាម្ចាស់ ដែលស្រឡាញ់គេ ។ ធម្មវិន័យក៏ចេញមកពីសេចក្តីស្រឡាញ់ដែរ ហេតុនេះហើយ អ្នកស្វែងរកព្រះយេស៊ូ ត្រូវរិះគិតអំពីការរស់នៅរបស់ខ្លួន ដើម្បីឲ្យគេប្រែរបៀបរស់នៅ ឲ្យបានស្របនឹងព្រះជាម្ចាស់ ដែលស្រឡាញ់គាត់ ។ អ្នក "*បង្រៀនព្រះគម្ពីរ*" ជាសាក្សី ដែលចែករំលែកការពិសោធន៍របស់ខ្លួន ដោយយោងពីការរស់នៅរបស់ខ្លួនផ្ទាល់ មិនមែនជាគ្រូ ដែលបង្រៀនសេចក្តីក្នុងគម្ពីរទេ ។

គេ "*ព្យាយាមអធិដ្ឋាន*" គឺ អ្នកស្វែងរក ទទួលការអប់រំឲ្យចេះអធិដ្ឋានដោយខ្លួនឯង តាមបែបជាគ្រីស្តបរិស័ទ ។ គ្រប់សាសនា អប់រំមនុស្សឲ្យចេះ ពាក្យអធិដ្ឋាន ឬ ឲ្យចេះសូត្រធម៌ ប៉ុន្តែមានតែព្រះយេស៊ូមួយព្រះអង្គទេ ដែលបង្ហាត់ឲ្យមានទំនាក់ទំនងពិសេសជាមួយព្រះបិតាដោយព្រះវិញ្ញាណបំភ្លឺ ។ ហេតុនេះ ត្រូវបង្ហាត់គេឲ្យអធិដ្ឋានតាមរបៀបព្រះយេស៊ូបង្ហាត់ក្នុង ម៉ាថាយ ៦:៥-១៣ ជាពិសេស ។ ពាក្យអធិដ្ឋាន "*ឱ!*

*ព្រះបិតាយើងខ្ញុំ"* ជាពាក្យអធិដ្ឋានគំរូរបស់គ្រីស្ទបរិស័ទ ។ អ្នកទទួលការអប់រំឲ្យចេះអធិដ្ឋាន ទូលព្រះបិតាដោយផ្ទាល់ ដោយចិត្តស្រឡាញ់ ដោយយកព្រះបន្ទូលរបស់ព្រះយេស៊ូផ្ទាល់មកទូល ដោយមានចិត្តគំនិតដូចព្រះយេស៊ូ ។

គេ *"ព្យាយាមរួមរស់ជាមួយគ្នា . . ."* គឺ គ្រីស្ទបរិស័ទដើមដំបូងយកទ្រព្យសម្បត្តិរបស់ខ្លួនមកចែកគ្នា ។ បានសេចក្តីថាគ្រីស្ទបរិស័ទរស់នៅតាមរបៀបផ្សេងពីអ្នកដទៃ ហើយមិនរកប្រយោជន៍ផ្ទាល់ខ្លួន ដោយគិតគូរដល់អ្នកក្រជាងខ្លួន ។ នេះជាចំណុចដ៏សំខាន់ បញ្ជាក់អំពីការប្រែចិត្តគំនិត មិនគ្រាន់តែដោយបបូរមាត់ប៉ុណ្ណោះទេ ។ អ្នកស្វែងរកព្រះយេស៊ូទទួលការអប់រំឲ្យរស់នៅតាមរបៀបព្រះយេស៊ូបានបង្ហាត់បង្រៀន គឺឲ្យស្រឡាញ់អ្នកដទៃ ឲ្យអត់ទោសឲ្យគេ ដែលសុទ្ធតែជាការប្លែកពីការមនុស្សលោកធ្លាប់ធ្វើជាធម្មតា ។ ពេលនោះ ត្រូវនឹកសញ្ជឹងអំពីសេចក្តីដែលព្រះយេស៊ូបង្រៀននៅលើភ្នំ (ម៉ាថាយ ៥-៧) គឺព្រះអង្គបង្ហាញផ្លូវទៅកាន់សុភមង្គល ដ៏ពិតប្រាកដ ប្លែកពីសុភមង្គល របស់មនុស្សលោកិយ ។ អ្នកណាក៏ត្រូវអនុវត្តតាមវិន័យរបស់លោកម៉ូសេដែរ មានតែគ្រីស្ទបរិស័ទទេ ដែលអនុវត្តតាមធម្មវិន័យថ្មីរបស់ព្រះយេស៊ូ ។

ដំណាក់កាលនេះយូរក្រែលដែរ ប្រហែលមួយ ឬ ពីរឆ្នាំ ។ ក្នុងតំណាក់កាលនេះ មានចាត់ចែងពិធីផ្សេងៗ ដូចជាពិធីបញ្ចូលពាក្យអធិដ្ឋានរបស់ព្រះយេស៊ូ (ម៉ាថាយ ៦:៩-១៣) គឺគ្រីស្ទបរិស័ទផ្តល់សក្ខីភាពអំពីរបៀប ដែលខ្លួនរស់នៅតាមពាក្យអធិដ្ឋាននេះ ឲ្យអ្នកស្វែងរកស្តាប់ ។ ជួនកាលមានចែងពិធីបញ្ជូនព្រះបន្ទូលរបស់ព្រះយេស៊ូ ស្តីអំពីសុភមង្គលដ៏ពិតប្រាកដ (ម៉ាថាយ ៥:១-១២) ។ ជួនកាលមានបញ្ជូន *"ធម៌ប្រកាសជំនឿ"* ជាសេចក្តីសង្ខេបនៃជំនឿរបស់គ្រីស្ទបរិស័ទ ដូចអភិបាលព្រះសហគមន៍បានចែងនៅក្រុងនីសេ (គ.ស ៣២៥) ។ ដូច្នេះ អ្នក

ចំណុលថ្មីអាចយល់ឃើញថា ខ្លួនទទួលជំនឿ ដែលក្រុមគ្រីស្តទូតបាន ប្រកាសមក តៗរហូតដល់សព្វថ្ងៃ ។

## ៣- ដំណាក់កាលរៀបចំខ្លួនឲ្យអគ្គសញ្ញាជ្រមុជទឹក និង ព្រះកាយព្រះគ្រីស្ត

តាំងពីជំនាន់មានចំនួនគ្រីស្តបរិស័ទជាច្រើន ព្រះសហគមន៍ចាត់ចែងរយៈពេលមួយ មុនបុណ្យចម្លង សម្រាប់ឲ្យគ្រីស្តបរិស័ទទាំងអស់រៀបចំខ្លួននឹងធ្វើពិធីលើកតំកើងព្រះយេស៊ូសោយទិវង្គត និង មានព្រះជន្មរស់ឡើងវិញ គឺអស់រយៈពេលជាសែសិបថ្ងៃ (lent) ។ ពេលនោះ ព្រះសហគមន៍ចាត់ចែងការអប់រំពិសេសសម្រាប់អ្នកស្វែងរកព្រះយេស៊ូ គឺឲ្យអានអត្ថបទគម្ពីរ ដែលរំឭកគ្រីស្តបរិស័ទអំពីអគ្គសញ្ញាជ្រមុជទឹក គឺអត្ថបទស្តីអំពីមារល្បួងព្រះយេស៊ូ (ម៉ាថាយ ៤:១-១១) ព្រះយេស៊ូសំដែងសិរីរុងរឿង (ម៉ាថាយ ១៧:១៩) ព្រះយេស៊ូមានព្រះបន្ទូលសន្ទនាជាមួយស្ត្រីស្រុកសាម៉ារី (យ៉ូហាន ៤:៥-៤២) ព្រះយេស៊ូប្រោសមនុស្សខ្វាក់តាំងពីកំណើតមកឲ្យភ្លឺ (យ៉ូហាន ៩:៤១) ព្រះយេស៊ូប្រោសលោកឡាសារឲ្យរស់ឡើងវិញ (យ៉ូហាន ១១-៤៤) ។ ព្រះសហគមន៍ទាំងមូលអប់រំអ្នកដែលចង់ទទួលអគ្គសញ្ញាជ្រមុជទឹក ក្នុងឱកាសបុណ្យចម្លង ឲ្យទទួលស្គាល់ផ្លូវរបស់ព្រះយេស៊ូ ដែលជាការតយុទ្ធប្រឆាំងនឹងមារ តែជាផ្លូវដែលនាំគេឆ្ពោះទៅកាន់សិរីរុងរឿង ។ ពេលគេទទួលអគ្គសញ្ញាជ្រមុជទឹក ព្រះយេស៊ូប្រោសប្រទានទឹកដែលផុសឡើង ផ្តល់ជីវិតអស់កល្បជានិច្ច ព្រះអង្គបំភ្លឺចិត្តគំនិតរបស់គេ ព្រះអង្គក៏ប្រោសគេឲ្យរស់ឡើងវិញដែរ ។

ធម្មតា លោកអភិបាលព្រះសហគមន៍ ធ្វើអគ្គសញ្ញាជ្រមុជទឹកជូនគេ នៅរាត្រីបុណ្យចម្លង ដើម្បីបញ្ជាក់យ៉ាងច្បាស់ថា អ្នកដែលទទួលអគ្គសញ្ញាជ្រមុជទឹក គឺរួមស្លាប់រួមរស់ជាមួយព្រះគ្រីស្ត ដែលសោយទិវង្គត

និង មានព្រះជន្មរស់ឡើងវិញ ដូចគ្រីស្តទូតប៉ូល ថែងថា៖ *"យើងទាំងអស់គ្នា ដែលបានទទួលពិធីជ្រមុជទឹក ដើម្បីរួមជាមួយព្រះ គ្រីស្តយេស៊ូ គឺយើងបានជ្រមុជរួមជាមួយព្រះអង្គ ដែលសោយទិវង្គត . . . រួមស្លាប់ជាមួយព្រះអង្គ យើងដូចជាបានចូលក្នុងផ្នូរជាមួយព្រះអង្គដែរ ។ . . . យើងក៏នឹងបានរួមជាមួយព្រះអង្គ ដែលមានព្រះជន្មរស់ឡើងវិញដែរ"* ។ (រ៉ូម ៦:៣ . . . ៥) ។

## ៤- ដំណាក់កាលទី ៤ ការរិះគិតអំពីជីវិតថ្មីដ៏អស្ចារ្យ ដែលគ្រីស្តបរិស័ទបានទទួលដោយសារព្រះគ្រីស្ត

ក្រោយបុណ្យចម្លង ហើយអស់រយៈពេលយ៉ាងហោចណាស់ ៥០ ថ្ងៃ ពន្លកថ្មី (neophyte) រិះគិតជាមួយគ្នាអំពីតម្លៃដ៏ថ្លៃថ្នូរនៃជីវិតរបស់ខ្លួន ។

★ ★ ★

បុព្វបុរសនៃព្រះសហគមន៍ពីដើម តែងប្រៀបធៀបមនុស្សពេញវ័យ ដែលសុំទៅជាគ្រីស្តបរិស័ទ ទៅនឹងការករកំណើតក្នុងផ្ទៃម្តាយ ឬទៅនឹងជនជាតិអ៊ីស្រាអែល ដែលធ្វើដំណើរចេញពីស្រុកអេស៊ីប ហើយចូលទៅទឹកដីកាណាន ។

ព្រះយេស៊ូ តែងប្រៀបធៀបអគ្គសញ្ញាជ្រមុជទឹកទៅនឹងកំណើតថ្មី (យ៉ូហាន ៣:៣-៨៖ *"ប្រសិនបើមនុស្សមិនកើតជាថ្មីទេ . . . ប្រសិនបើមនុស្សមិនកើតពីទឹក និង ពីព្រះវិញ្ញាណទេ គេពុំអាចចូលក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់បានឡើយ"* ) ។ ប៉ុន្តែមនុស្សធ្លាប់មានជីវិតក្នុងផ្ទៃម្តាយ ៩ ខែ មុននឹងកើតជាទារក ។ ម្តាយទទួលមេជីវិតពីស្វាមីយ៉ាងណា អ្នកជឿក៏ទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់យ៉ាងនោះដែរ ។ ពេលគេទទួល

ដំណើងល្អដើមដំបូង ជំនឿរបស់គេ ហាក់ដូចជា *"ចាប់ផ្ទៃ"* តែជំនឿនេះនៅតូចនៅឡើយ ដូចទារកក្នុងផ្ទៃម្ដាយ ។ ពេលនោះ អ្នកស្វែងរកព្រះយេស៊ូ ធ្វើកាយវិការផ្សេងៗបញ្ជាក់ថា ខ្លួនសុខចិត្តដើរតាមព្រះអង្គ ដែលត្រាស់ហៅគេ គេចង់ស្គាល់ព្រះអង្គទុកជាព្រះបរមគ្រូរបស់ខ្លួនឲ្យកាន់តែច្បាស់ឡើងៗ ហើយគេសម្រេចចិត្តផ្ញើជីវិតទាំងស្រុងលើព្រះអង្គ ដែលជាប្រភពនៃជីវិតដ៏ពិតប្រាកដ ។ អ្នកនោះចាប់ផ្ដើមជឿ ហើយនៅពេលនោះគាត់ *"ចូលក្នុងព្រះសហគមន៍"* ដោយមានពិធីដ៏ឱឡារិកមួយ ។ ពេលគេចូលព្រះសហគមន៍ហើយនោះគេទៅជា *"គ្រីស្តបរិស័ទ"* ហើយ ។

ក្នុងផ្ទៃម្ដាយ កូនត្រូវការពេលវេលាយ៉ាងយូរ ដើម្បីចំរើនឡើងយ៉ាងណា អ្នកដែលប្រែចិត្តគំនិតទទួលព្រះយេស៊ូទុកជាព្រះសង្គ្រោះ ក៏ត្រូវការពេលវេលាយ៉ាងយូរដែរ ដើម្បីហាត់ខ្លួនឲ្យរស់នៅតាមព្រះឱវាទរបស់ព្រះអង្គ ។ គេមិនត្រូវ *"រៀន"* ទេ គឺគេត្រូវហាត់ខ្លួនឲ្យរស់នៅតាមព្រះគ្រីស្ត គឺគេដើរតាមព្រះអង្គ ដែលគេបានជួប គឺព្រះដែលមានព្រះជន្មគង់នៅ ។

ការប្រៀបធៀបបែបនេះ ជួយបំភ្លឺឲ្យយើងយល់ថា ត្រូវទុកពេលវេលាយ៉ាងយូរ ដើម្បីឲ្យជំនឿនេះចំរើនឡើង ដូចកូនក្នុងផ្ទៃត្រូវការពេលវេលាយ៉ាងយូរ ដើម្បីទៅជាទារកដ៏ពិតប្រាកដ ។ បើកូនកើតត្រូវតាមពេលកំណត់ វារស់បាន ប្រសិនបើវាកើតមុនពេលកំណត់ វារលូត មិនអាចរស់បានទេ ប្រសិនបើវាកើតយឺតពេលពេក វាក៏ត្រូវស្លាប់ក្នុងផ្ទៃម្ដាយដែរ ។ ហេតុនេះ កុំធ្វើអគ្គសញ្ញាជ្រមុជទឹកមុនពេលកំណត់ គឺនៅពេលគេមិនទាន់មានជំនឿគ្រប់គ្រាន់ ក្រែងជំនឿរបស់គេសាបសូន្យ ។ កុំពន្យារពេលយូរពេក ក្រែងគេណាយចិត្ត ហើយជំនឿនេះក៏ស្លាប់ដែរ ។

ម្យ៉ាងទៀត ការប្រៀបធៀបនេះជួយបំភ្លឺ ឲ្យយើងដឹងថា ការអប់រំអ្នកស្វែងរកព្រះយេស៊ូពុំមែនជា *"ការបង្រៀន"* ទេ គឺជាការបង្ហាត់ឲ្យគេរស់នៅតាមរបៀបព្រះគ្រីស្តវិញ ។ ព្រះសហគមន៍ទាំងមូលប្រៀបដូចជា

ម្តាយ ដែលចិញ្ចឹមកូនក្នុងផ្ទៃ គឺមិនគ្រាន់តែមានពីរ ឬ បីនាក់ទទួលភារកិច្ចនេះទេ ។ ក្រុមគ្រីស្ទបរិស័ទទាំងអស់អប់រំគេ ដោយធ្វើជាគំរូឲ្យគេ ដោយស្រឡាញ់គ្នាយ៉ាងពិតប្រាកដ ដោយចាត់ចែងពិធីបុណ្យផ្សេងៗ ។ អ្នកស្វែងរកព្រះយេស៊ូ ក៏ជួយឲ្យព្រះសហគមន៍បំពេញមុខនាទីរបស់ខ្លួនជាម្តាយដែរ គឺឲ្យមានចិត្តល្អ ចេះអប់រំ យកចិត្តទុកដាក់នឹងចិញ្ចឹមគេ ។

បុព្វបុរសនៃព្រះសហគមន៍ ក៏តែងតែប្រៀបធៀបការបង្ហាត់អ្នកស្វែងរកព្រះយេស៊ូ ទៅនឹងដំណើរចេញពីស្រុកអេស៊ីបទៅកាន់ទឹកដីកាណានដែរ ។ ព្រឹត្តិការណ៍នេះមានសារៈសំខាន់យ៉ាងខ្លាំងក្នុងប្រវត្តិនៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់ត្រាស់ហៅប្រជារាស្ត្រព្រះអង្គឲ្យរួចផុតពីទាសករនៅស្រុកអេស៊ីប ព្រះអង្គប្រោសគេឲ្យឆ្លងកាត់សមុទ្រក្រហម និង ប្រទានធម្មវិន័យនៅលើភ្នំស៊ីណៃ ។ ព្រះអង្គហាក់ដូចជាមានព្រះបន្ទូលថា *"យើងស្រឡាញ់អ្នករាល់គ្នាហើយ តើអ្នករាល់គ្នាសុខចិត្តស្រឡាញ់យើងឬទេ? យើងមានព្រះបន្ទូល តើអ្នករាល់គ្នាសុខចិត្តប្រព្រឹត្តតាមឬទេ?"* ។ ជនជាតិអ៊ីស្រាអែលបានប្រព្រឹត្តអំពើបាបដោយថ្វាយបង្គំរូបគោ ហេតុនេះ ព្រះជាម្ចាស់ល្បងលមើលចិត្តគេអស់រយៈពេលសែសិបឆ្នាំ ។

លោក អូរីសែន ជាជនជាតិអេស៊ីបម្នាក់ រស់នៅសតវត្សទី ២ នៃ គ.ស ។ លោកជាគ្រូអប់រំជំនឿដ៏ចំណានម្នាក់ លោកធ្លាប់លើកឧទាហរណ៍នេះ ដើម្បីអប់រំអ្នកស្វែងរកព្រះយេស៊ូថា *"បងប្អូនបានឃ្លាតចាកពីពិភពលោកនៃសាសន៍ដទៃ បានលះបង់ចោលការគោរពព្រះដទៃនៅស្រុកអេស៊ីបហើយ! បងប្អូនបានចូលក្នុងប្រជារាស្ត្ររបស់ព្រះជាម្ចាស់ហើយ ។ បងប្អូនចាប់ផ្តើមដើរ ។ ពេលបងប្អូនទទួលការអប់រំខាងជំនឿ ប្រៀបដូចជាទៅនឹងពេលដែលប្រជាជនអ៊ីស្រាអែលដើរក្នុងវាលរហោស្ថាន ។ បងប្អូនបានទទួលធម្មវិន័យរបស់លោកម៉ូសេ និង ធម្មវិន័យរបស់ព្រះយេស៊ូ ហើយហាត់ខ្លួនឲ្យរស់នៅតាមរបៀបព្រះអង្គប្រៀន*

*ប្រដៅនោះ ។ ពេលបងប្អូនបានហាត់ខ្លួនឲ្យរស់នៅតាមរបៀបថ្មីនោះរួច អស់លោកបូជាចារ្យនឹងជូនដំណើរបងប្អូន ឲ្យឆ្លងទន្លេយ័រដាន់ ហើយបងប្អូនបានទទួលពិធីជ្រមុជទឹកក្នុងទន្លេយ័រដាន់ដូចព្រះគ្រីស្តដែរ ។ បន្ទាប់មកបងប្អូននឹងចូលក្នុងទឹកដីសន្យា ទៅសម្រាប់រួមជាមួយព្រះគ្រីស្ត"* ។

ការប្រៀបធៀប ក៏ជួយបំភ្លឺឲ្យយល់ថា ជំនឿប្រៀបដូចជាការធ្វើដំណើររួមជាមួយព្រះយេស៊ូ គឺមានដំណាក់កាលផ្សេងៗ ។ អ្នកស្វែងរកព្រះយេស៊ូ ធ្វើដំណើរជាមួយព្រះសហគមន៍ទាំងមូល ពួកគេស្តាប់ព្រះបន្ទូលរួមជាមួយគ្រីស្តបរិស័ទឯទៀតៗ ។ ដំណើរនេះ ជាការពិបាកបន្តិច ប៉ុន្តែ ត្រូវខិតខំរស់នៅឲ្យបានកាន់តែប្រសើរឡើងៗ តាមដំណឹងល្អរបស់ព្រះយេស៊ូ ។

អស់លោកក៏ធ្លាប់ប្រៀបធៀបអគ្គសញ្ញាជ្រមុជទឹក ទៅនឹងអាពាហ៍ពិពាហ៍ គឺមានដំណាក់កាលផ្សេងៗដែរ មានចូលដណ្តឹង ភ្ជាប់ពាក្យ លើកជំនូន រៀបការ រស់នៅជាមួយគ្នា ។

★ ★ ★

របៀបព្រះសហគមន៍កាតូលិក អប់រំអ្នកស្វែងរកព្រះយេស៊ូ ជារបៀបគ្រីស្តបរិស័ទធ្លាប់ធ្វើតាំងពីដើមរៀងមក ។ ព្រះជាម្ចាស់ទាក់ទាញចិត្តមនុស្សឲ្យជឿ តែយើងជាគ្រីស្តបរិស័ទក៏មានភារកិច្ចអប់រំជំនឿដែរ ។ លោក អូរីសែន បញ្ជាក់ថា *"គេមកជិតជំនឿ គេចូលក្នុងជំនឿ គេបញ្ជាក់ជំនឿ និង រស់នៅតាមជំនឿ"* ។ ព្រះយេស៊ូក៏សព្វព្រះហឫទ័យឲ្យអ្នកជឿរួមគ្នាជាមហាគ្រួសារ ដែលយកចិត្តទុកដាក់នឹងរស់នៅតាមរបៀបថ្មី និងកែប្រែទ្រង់ទ្រាយពិភពលោកនេះ ឲ្យបានសមនឹងព្រះហឫទ័យព្រះអង្គ ។ ជំនឿមានឥទ្ធិពលក្នុងដំណើរនៃពិភពលោក ។